**នរោត្តម សីហនុ**

**នៃកម្ពុជា**

**និង**

**សម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតា**

**នរោត្តម មុនិនាថ សីហនុ**

**នៃព្រះរាជាណាចក្រកម្ពុជា**

ជូន ឯកឧត្តម គាត ឈន់
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង
ហិរញ្ញវត្ថុ

ឯកឧត្តមជាទីរាប់អានដ៏ខ្ពង់ខ្ពស់ និងស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត

យើងខ្ញុំបានទទួលហើយលិខិតថ្វាយពរដ៏ល្អប្រពៃ នៅក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិយើង ហើយសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅឯកឧត្តមដែលផ្ដល់យុត្តិធម៌ជូនសង្គមរាស្ត្រនិយម និងដល់យើងខ្ញុំ ក្នុងការបំរើប្រជាជាតិ មាតុភូមិ និងប្រជារាស្ត្រកម្ពុជា។

នៅក្នុងឱកាសដ៏ល្អប្រសើរនេះ យើងខ្ញុំសូមសំដែងនូវការសរសើរដ៏កក់ក្ដៅឯកឧត្តមដែលជាអ្នកស្នេហាជាតិដ៏ប្រពៃ ជារៀងដរាប ហើយទទួលបានជោគជ័យជាច្រើនក្នុងការបំរើឧត្តមប្រយោជន៍ប្រជាជាតិ និងប្រជារាស្ត្រកម្ពុជា។

យើងខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានប្រកបតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមឯកឧត្តម និងលោកជំទាវ ទទួលនូវសេចក្ដីរាប់អានដ៏ខ្ពង់ខ្ពស់ និងស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត អំពីយើងខ្ញុំ។

ន សីហនុ

ន មុនិនាថ សីហនុ

**នរោត្តម សីហនុ** **នរោត្តម មុនិនាថ សីហនុ**

ភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១១